# ចំណុចសំខាន់ៗនៃគោលការណ៍ណែនាំ

## ការទប់ស្កាត់



## ការត្រៀមលក្ខណៈទុកជាមុន






## ការឆ្លើយតប



## ការស្តារឡើងវិញ



# តើអ្វីទៅការគ្រប់គ្រងភ្លើងឆេះតាមបែបចម្រុះ?

ការគ្រប់គ្រងភ្លើងឆេះតាមបែបចម្រុះ (IFM) មានគោលបំណងដោះស្រាយបញ្ហាដែលបង្កឡើងដោយភ្លើងឆេះដោយចៃដន្យ នៅក្នុងបរិបទនៃប្រព័ន្ធធម្មជាតិ និងសេដ្ឋកិច្ចសង្គម ដោយបញ្ចូលគ្នារវាងសមាសភាគ ដូចជា៖ ការទប់ស្កាត់ ការត្រៀមលក្ខណៈទុកជាមុន ការឆ្លើយតប និងការស្តារឡើងវិញ (PPRR) ក្នុងការគ្រប់គ្រងភ្លើងឆេះ។ គោលការណ៍ណែនាំនេះបានណែនាំឱ្យអ្នកពាក់ព័ន្ធទាំងអស់អនុវត្តសកម្មភាពសមស្របទៅតាមពេលវេលា និងកម្រិត ដើម្បីត្រៀមលក្ខណៈទុកជាមុន និងដើម្បីគ្រប់គ្រងស្ថានភាពភ្លើងឆេះ។




## វដ្តនៃការគ្រប់គ្រងភ្លើងឆេះតាមបែបចម្រុះ

បច្ចុប្បន្ននេះ ធនធានដែលបានបែងចែកសម្រាប់ការទប់ស្កាត់គឺពុំគ្រប់គ្រាន់។ IFM ណែនាំឱ្យបែងចែកធនធាន 70% សម្រាប់ការទប់ស្កាត់ភ្លើងឆេះ និងបែងចែកធនធានដែលនៅសល់សម្រាប់ការត្រៀមលក្ខណៈទុកជាមុន ការឆ្លើយតប និងការស្តារឡើងវិញ។ ការគ្រប់គ្រងជលសាស្ត្រ គឺជាផ្នែកមួយ ដ៏សំខាន់បំផុត ក្នុងការធានានិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីតំបន់ដីមមោក និងការទប់ស្កាត់ភ្លើងឆេះ។ នៅក្នុងស្ថានភាពដែលមិនមានការរំខាន តំបន់ដីមមោកទាំងនោះកម្រនឹងឆេះណាស់។



# រចនាសម្ព័ន្ធ

គោលការណ៍ណែនាំផ្តោតលើប្រធានបទចំនួនប្រាំដែលមានទំនាក់ទំនងគ្នា៖ ១) គោលនយោបាយ និងបទប្បញ្ញត្តិ ២) ព័ត៌មាន និងចំណេះដឹង ៣) ការធ្វើផែនការ និងការសម្របសម្រួល ៤) ធនធាន និង ៥) ទំនាក់ទំនងសាធារណៈ។ ជាពិសេសសម្រាប់ការទប់ស្កាត់ភ្លើងឆេះ ប្រធានបទបន្ថែមមួយទៀតនោះគឺ វិធានការទប់ស្កាត់ភ្លើងឆេះនៅតំបន់ដីមមោក ។




# ការទប់ស្កាត់

## គោលនយោបាយ និងបទប្បញ្ញត្តិ

ការដាក់ចេញនូវបទប្បញ្ញត្តិ និងគោលនយោបាយថ្នាក់ជាតិសម្រាប់ការការពារ និងការប្រើប្រាស់តំបន់ដីមមោកប្រកបដោយនិរន្តរភាព គឺជាជំហានសំខាន់ដំបូងដើម្បីឆ្ពោះទៅរកការគ្រប់គ្រងភ្លើងឆេះ នៅតំបន់ដីមមោក។ គោលនយោបាយ និងបទប្បញ្ញត្តិទាំងនោះ ត្រូវមានវិធីសាស្ត្រប្រកបដោយតុល្យភាពដើម្បីបង្ហាញ ថាការបង្ហូរទឹកចេញពីតំបន់ដីមមោក ក្នុងគោលបំណងធ្វើកសិកម្មជាលក្ខណៈពាណិជ្ជកម្មគឺមិនមែនជាការអនុវត្តប្រកបដោយនិរន្តរភាពនោះទេ។ ការកំណត់តំបន់សម្រាប់ការប្រើប្រាស់ដីដែលសមស្របគួរតែមានការគិតគូរពីការកាត់បន្ថយការប្រើប្រាស់ដីមមោកឱ្យបានតិចបំផុតសម្រាប់ការអភិវឌ្ឍ។ អង្គភាពសម្រាប់គ្រប់គ្រងជលសាស្ត្រគួរតែត្រូវបានបង្កើតឡើង ដើម្បីរក្សាកម្រិតទឹកឱ្យបានសមស្រប និងកាត់បន្ថយភាពងាយរងគ្រោះចំពោះការបាក់ស្រុតតំបន់ដីមមោក។ ជាចុងក្រោយ តំបន់ដីមមោកចាំបាច់ត្រូវតែចាត់ទុកថាជាផ្នែករួមបញ្ចូលមួយដ៏សំខាន់នៅក្នុងការការពារប្រព័ន្ធអេកូឡូស៊ីតំបន់ទេសភាពទំនាប និងតំបន់ឆ្នេរ។

## វិធានការទប់ស្កាត់ភ្លើងឆេះនៅតំបន់ដីមមោក

វាពិតជាសំខាន់ខ្លាំងណាស់ក្នុងការទប់ស្កាត់ភ្លើងឆេះតាមរយៈការពង្រឹងការគ្រប់គ្រងដី និងទឹក ព្រមទាំងការលើកកម្ពស់វិធីសាស្ត្រក្នុងការគ្រប់គ្រង និងការអភិវឌ្ឍដី ដែលអាចជួយកាត់បន្ថយហានិភ័យដែលបង្កឱ្យមានភ្លើងឆេះ។ វិធីសាស្ត្រដ៏សំខាន់បំផុតក្នុងន័យនេះ គឺការគ្រប់គ្រងទឹក។ លើសពីនេះទៅទៀត ការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ប្រព័ន្ធកសិរុក្ខកម្មជាជាងការដាំដំណាំប្រចាំឆ្នាំ ក៏អាចជួយទប់ស្កាត់ភ្លើងឆេះនៅតំបន់ដីមមោក និងជួយបង្កើនប្រាក់ចំណូលផងដែរ ដែលអាចចូលរួមក្នុងការកាត់បន្ថយហានិភ័យនៃភ្លើងឆេះផងដែរ។

## ព័ត៌មាន និងចំណេះដឹង

ការយល់ដឹងអំពីស្ថានភាពរបស់តំបន់គឺជាគន្លឹះសម្រាប់អ្នកសម្រេចចិត្តក្នុងការ រៀបចំផែនការ និងបែងចែកធនធាន។ ដូច្នេះ ព័ត៌មានអំពីលក្ខណៈភូមិសាស្ត្រនៃដី ផ្លូវ រុក្ខជាតិ ដី ប្រវត្តិនៃភ្លើងឆេះ ហេដ្ឋារចនាសម្ព័ន្ធ ប្រជាសាស្ត្រ ស្ថានភាពសេដ្ឋកិច្ចសង្គម និងកម្មសិទ្ធិដីធ្លីត្រូវតែមានការប្រមូល និងធ្វើបច្ចុប្បន្នភាព។របាយការណ៍គួរតែត្រូវបានធ្វើឡើងដើម្បីស្វែងយល់ពីដើមហេតុ លក្ខណៈតំបន់ និងផលប៉ះពាល់បន្ទាប់ពីមានភ្លើងឆេះ។ ទិន្នន័យគួរតែត្រូវបានវិភាគដើម្បីផ្តល់ជាបរិបទសម្រាប់ធ្វើការគ្រប់គ្រង និង ត្រួតពិនិត្យឱ្យកាន់តែប្រសើរឡើងនាពេលអនាគត។



## ការធ្វើផែនការ និងការសម្របសម្រួល

ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការបញ្ចូលកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលដល់ភាគីពាក់ព័ន្ធទាំងអស់។ ការល្បាតជាញឹកញាប់លើតំបន់ដែលចាត់ទុកថាមានហានិភ័យខ្ពស់ ដោយប្រព័ន្ធវាយតម្លៃគ្រោះថ្នាក់ពីភ្លើងឆេះ (FDRS) គួរតែត្រូវបានធ្វើឡើង។

## ធនធាន

ការផ្គត់ផ្គង់ឧបករណ៍ពន្លត់ភ្លើងឆេះ រួមទាំងបរិក្ខារ និងសម្ភារប្រើប្រាស់ត្រូវមានភាពសមស្របនឹងលក្ខណៈភូមិសាស្ត្រ ហើយត្រូវថែទាំ និងទិញស្តុកទុកឡើងវិញនៅពេលប្រើប្រាស់រួច។ វគ្គបណ្តុះបណ្តាលសម្រាប់ការគ្រប់គ្រងភ្លើងឆេះតំបន់ដីមមោក គឺមានសារៈសំខាន់ និងតម្រូវឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅនឹងព័ត៌មានលម្អិតជាច្រើនដូចជា សម្ភារ ពេលវេលានៃការបណ្តុះបណ្តាល និងការគ្រប់គ្រងធនធានមនុស្ស ពោលគឺនរណាបានទទួលការបណ្តុះបណ្តាល និងក្នុងគោលបំណងអ្វី។

## ការអប់រំផ្សព្វផ្សាយជាសាធារណៈ

ក្រុមការងារអប់រំផ្សព្វផ្សាយក្នុងអង្គភាពគ្រប់គ្រងភ្លើងឆេះត្រូវតែដឹងអំពីតម្រូវការរបស់សាធារណៈជន និងផ្តល់ព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយដោយមិនបង្កឱ្យមានភាពអាសន្នដល់សហគមន៍។ លើសពីនេះទៀតពួកគេក៏ត្រូវដកស្រង់ និងផ្ទេរព័ត៌មានទៅ អាជ្ញាធរពាក់ព័ន្ធ ដើម្បីគ្រប់គ្រងស្ថានការណ៍បន្ទាន់នានា។

# ការត្រៀមលក្ខណៈទុកជាមុន

## គោលនយោបាយ និងបទប្បញ្ញត្តិ

ការត្រៀមលក្ខណៈទុកមុនបានល្អ គឺមានសារៈសំខាន់ដើម្បីធានាបាននូវការឆ្លើយតបសមស្របបំផុត ដើម្បីកាត់បន្ថយការចំណាយលើការពន្លត់ភ្លើង និងការខាតបង់ដោយសារភ្លើងឆេះ។ ការឆ្លើយតបបានកាន់តែលឿនចំពោះបញ្ហាភ្លើងឆេះនៅក្នុងដំណាក់កាលដំបូង ធ្វើឱ្យមានការចំណាយទាបក្នុងការពន្លត់ភ្លើង។ ដូច្នេះ ជាការល្អ គួរតែបែងចែកធនធានឱ្យបានសមស្របដើម្បីធ្វើការពន្លត់ភ្លើងឱ្យបានភ្លាមៗមុននឹងមានការរាលដាលធំ។

## ព័ត៌មាន និងចំណេះដឹង

ផែនទីនៃតំបន់ដែលមានហានិភ័យភ្លើងឆេះខ្ពស់ ទីតាំងអ្នកពន្លត់ភ្លើងឈរជើង និងទីតាំងទុកដាក់ធនធានសម្រាប់ពន្លត់ភ្លើង អាចរៀបចំឡើង និងចែកចាយដល់ភាគីដែលពាក់ព័ន្ធបាន។ម្យ៉ាងវិញទៀត ប្រទេសសមាជិកអាស៊ានមានសមត្ថភាពក្នុងការព្យាករណ៍ហានិភ័យនៃភ្លើងឆេះតាមរយៈ FDRS។ FDRS ដើរតួជាប្រព័ន្ធផ្តល់ព័ត៌មានឆាប់រហ័សដើម្បីត្រៀមលក្ខណៈ សម្រាប់រដូវកាលដែលងាយនឹងកើតមានភ្លើងឆេះនាពេលខាងមុខ ហើយប្រទេសសមាជិកអាស៊ានក៏អាចចូលមើលព័ត៌មានអំពីតំបន់ដែលមានភ្លើងឆេះប្រចាំថ្ងៃផងដែរ។

## ការធ្វើផែនការ និងការសម្របសម្រួល

សកម្មភាពនេះ រួមមានការធានាថាបុគ្គលិក/មន្ត្រីសំខាន់ៗគឺនៅប្រចាំការ ហើយធនធានគួរតែត្រូវបានរៀបចំសម្រាប់ការប្រើប្រាស់ភ្លាមៗនៅពេលចាំបាច់។ ហ្វឹកហាត់ និងការសាកល្បងអនុវត្តត្រូវបានធ្វើឡើង ដើម្បីធានាថាបុគ្គលិក/មន្ត្រីប្រចាំការស្វែងយល់បានច្បាស់អំពីនីតិវិធីប្រតិបត្តិការស្តង់ដារ ហើយដើម្បីធានាថាឧបករណ៍គឺរួចរាល់ជាស្រេចសម្រាប់ការធ្វើប្រតិបត្តិការ។ ការល្បាតជាប្រចាំគួរតែត្រូវបានធ្វើឡើងដោយអនុលោមតាម FDRS។

## ធនធាន

តំបន់ដីមមោក ត្រូវការធនធានបន្ថែមក្នុងការឆ្លើយតបនឹងភ្លើងឆេះ ជាពិសេសឧបករណ៍ឯកទេសសម្រាប់ប្រើជាមួយតំបន់ដីមមោក។ ស្វែងយល់ពីការរៀបចំផ្សេងៗ ដើម្បីទិញឧបករណ៍ទាំងនោះ។



រៀបចំវគ្គបណ្តុះបណ្តាលរួមគ្នា គឺជាវិធីមួយផ្សេងទៀតដើម្បីចែករំលែកធនធាន និងពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធមុនពេលរដូវកាលភ្លើងឆេះចាប់ផ្តើម។

## ការផ្សព្វផ្សាយជាសាធារណៈ

ការបន្តនូវការអប់រំផ្សព្វផ្សាយជាសាធារណៈ អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ភ្លើងដោយធ្វេសប្រហែសអាចជួយបង្កើតទម្លាប់ល្អក្នុងសង្គម ដើម្បីកាត់បន្ថយឧប្បត្តិហេតុភ្លើងឆេះក្នុងតំបន់ដីមមោក។ របាយការណ៍ធាតុអាកាសប្រចាំថ្ងៃ និងសេចក្តីប្រកាសព័ត៌មានគួរតែរួមបញ្ចូលព័ត៌មាន FDRS ស្តីពីទិដ្ឋភាពទូទៅ និងលក្ខខណ្ឌធាតុអាកាស។ ការដំឡើងផ្ទាំង FDRS និងការជូនដំណឹងដល់សហគមន៍អំពីការប្រើប្រាស់ផ្ទាំងនេះក៏ជាការចាំបាច់ផងដែរ។ យន្តការ និងឧបករណ៍ដើម្បីទទួលបានព័ត៌មាន និងមតិកែលម្អពីសាធារណជន គួរតែត្រូវបានផ្តល់ជូន។


©Rini Sulaiman/Norwegian Embassy

# ការឆ្លើយតប

## គោលនយោបាយ និងបទប្បញ្ញត្តិ

គោលនយោបាយ និងបទប្បញ្ញត្តិស្តីពីការឆ្លើយតបទៅនឹងការ ពន្លត់ភ្លើងតែងតែផ្តោតលើសូចនាករអនុវត្តការងារ។ ឧទាហរណ៍ នៅពេលដែលឃើញមានភ្លើងឆេះ គោលការណ៍ណែនាំស្តីពីរយៈពេលរំពឹងទុកដែលអាចពន្លត់ភ្លើងក្នុងទំហំជាក់លាក់មួយអោយរលត់ទាំងស្រុងបាន អាចប្រើជា "សូចនាករអនុវត្តការងារ"។ អាចមានការផ្តល់ជារង្វាន់ ឬការទទួលស្គាល់ក្នុងទម្រង់ណាមួយ ប្រសិនបើសូចនាករអនុវត្តការងារត្រូវសម្រេចបានដោយក្រុមការងារពន្លត់ភ្លើង ឬសហគមន៍ណាមួយ។ បន្ទាប់មកក្រុមការងារ/ក្រុមទាំងនេះអាចទទួលបានការអញ្ជើញឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងចែករំលែកការអនុវត្តល្អបំផុត ដើម្បីលើកកម្ពស់សមត្ថភាពអ្នកពាក់ព័ន្ធនៅទូទាំងប្រទេស។

## ព័ត៌មាន និងចំណេះដឹង

របាយការណ៍ស្តីពីស្ថានភាពភ្លើងឆេះ (SitReps) មានសារៈសំខាន់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងការវិភាគពីតម្រូវការ។ SitRep គួរតែត្រូវបានរៀបចំជារៀងរាល់ថ្ងៃសម្រាប់បញ្ហាភ្លើងឆេះ ហើយបញ្ជូនទៅទីស្នាក់ការកណ្តាលដើម្បីធ្វើបច្ចុប្បន្នភាពពីតម្រូវការធនធាន និងលទ្ធផលរំពឹងទុក។ លើសពីនេះ ភ្នាក់ងារពន្លត់ភ្លើងត្រូវតាមដានព័ត៌មានអំពី ស្ថានភាពនិងការព្យាករណ៍ធាតុអាកាស FDRS និងព័ត៌មានអំពីតំបន់ដែលមានភ្លើងឆេះ។.

## ការធ្វើផែនការ និងការសម្របសម្រួល

ផែនការឆ្លើយតបបឋម ត្រូវតែធ្វើឡើងឱ្យបានឆាប់រហ័ស នៅពេលដែលមានការរាយការណ៍ពីករណីដែលមានភ្លើងឆេះ ដោយប្រើផែនការកែនកម្លាំងដើម្បីពន្លត់ភ្លើង ដែលបានរៀបចំឡើងនៅក្នុងដំណាក់កាលត្រៀមលក្ខខណៈ។ បណ្តាប្រទេសក្នុងតំបន់អាស៊ានអាចប្រើប្រាស់ប្រព័ន្ធបញ្ជាពេលមានឧប្បត្តិហេតុ ដើម្បីគ្រប់គ្រងក្រុមការងារពន្លត់ភ្លើងបន្ទាន់ ដូច្នេះទាំងក្រុមការងារនៃផែនការកែនកម្លាំង និងក្រុមការងារគ្រប់គ្រងបញ្ហាភ្លើងឆេះអាចធ្វើការរួមគ្នាបានយ៉ាងឆាប់រហ័ស។

- បង្កើតសូចនាករអនុត្តការងារគ្រប់គ្រង-១.ធ្វើការពន្លល់ភ្លើងក្នុងរយៈពេលកំណត់ណាមួយ កាត់បន្ថយការបង្កឱ្យមានភ្លើងឆេះ/ក្នុងមួយស្រុកៗ កាត់បន្ថយសន្ទស្សន៍ស្តង់ដារបំពុល PSI នៅក្នុងរដូវកាលណាមួយ

- ការផ្សព្វផ្សាយជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយ - ១. ព័ត៌មានថ្មីៗអំពីភ្លើងឆេះ តំបន់គ្រោះថ្នាក់ដែលត្រូវជៀសវាង សារនិងការណែនាំពីសុខភាពសាធារណៈ

- របាយការណ៍ស្តីពីស្ថានភាពប្រចាំថ្ងៃ ( SitReps )
- ព័ត៌មានលក្ខណៈវិទ្យាសាស្ត្រអំពីភ្លើងឆេះ - ១.របាយការណ៍ធាតុអាកាសប្រចាំថ្ងៃ ការវាយតម្លៃពីគ្រោះថ្នាក់ដែលអាចកើតឡើងពេលដែលមានភ្លើងឆេះប្រព័ន្ធជលសាស្ត្រស្ថានភាពដែលអាចបង្កឱ្យមានភ្លើងឆេះ




- ការអនុវត្ត "ផែនការឆ្លើយតបបឋម" និងការប្រើប្រាស់ប្រព័ន្ធបញ្ជាពេលមានឧប្បត្តិហេតុ
- ការរៀបចំជាបន្តបន្ទាប់នូវផែនការ "ការពន្លត់ជាចម្បង" ១.វិធីសាស្ត្រផ្អែកលើស្ថានភាពតំបន់និងការប្រើប្រាស់ទំនប់ស្នាក់ទឹកដើម្បី បង្ហូរទឹកពន្លត់ភ្លើង
- ការសម្របសម្រួល និងជំនួយបន្ថែមជា ធនធានដែលត្រៀមរួចជាស្រេចពីភ្នាក់ងារពាក់ព័ន្ធ ដៃគូសហការ និងស្រុក ឬខេត្តដែលនៅជុំវិញ។

- ប្រើប្រាស់វិធីសាស្ត្រពន្លត់ភ្លើងទាំងអស់ភ្លាមៗដើម្បីកាត់បន្ថយការចំណាយ និងការខាតបង់
- ប្រើឧបករណ៍ដែលសមស្រប និងឧបករណ៍ឯកទេស
- ត្រូវប្រាកដថាមានការផ្គត់ផ្គង់សម្ភារពន្លត់ភ្លើងជាមូលដ្ឋាន
- អនុវត្តប្រព័ន្ធបញ្ជាពេលមានឧប្បត្តិហេតុដើម្បីគ្រប់គ្រងពេលមានបញ្ហាភ្លើងឆេះ

### ធនធាន

ធនធានគួរតែមានសម្រាប់អនុត្តការងារ ដូចជាឧបករណ៍ប្រើដោយដៃ ឧបករណ៍ឯកទេស និងអ្នកដែលនឹងប្រើប្រាស់ឧបករណ៍ទាំងនោះ។

### ការផ្សព្វផ្សាយជាសាធារណៈ

ការជូនដំណឹងដល់សាធារណជនឱ្យបានដឹងអំពីស្ថានភាពនៅទីវាល និងគុណភាពខ្យល់ គឺមានសារៈសំខាន់ណាស់សម្រាប់សាធារណជន ដើម្បីគេចពីតំបន់ដែលមានភ្លើងឆេះ និងកំណត់នូវអ្វីដែលល្អបំផុតសម្រាប់សុវត្ថិភាពរបស់ពួកគេ។

# ការស្តារឡើងវិញ

## គោលនយោបាយ និងបទប្បញ្ញត្តិ

គោលនយោបាយ និងបទប្បញ្ញត្តិគួរតែត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីនៃទីតាំងដែលបានឆេះ ព្រោះវានឹងជួយកាត់បន្ថយហានិភ័យដែលបង្កឱ្យមានភ្លើងឆេះនាពេលអនាគត។ លើសពីនេះទៀត វាពិតជាសំខាន់ខ្លាំងណាស់ក្នុងការយកចិត្តទុកដាក់លើការគ្រប់គ្រងដោយប្រុងប្រយ័ត្នចំពោះសុខុមាលភាពសង្គម ដោយសារភ្លើងឆេះនៅតំបន់ដីមមោក ជាទូទៅតែងតែកើតឡើងដោយការផ្លាស់ប្តូរតម្រូវការសង្គម និងសេដ្ឋកិច្ច។

## ព័ត៌មាន និងចំណេះដឹង

គណៈបញ្ជាការគ្រប់គ្រង និងអ្នកគ្រប់គ្រងការពន្លត់ភ្លើង ត្រូវរាយការណ៍អំពីការខូចខាត និងការបាត់បង់ដែលបណ្តាលមកពីភ្លើងឆេះ មុនពេលបញ្ចប់ការងាររបស់ពួកគេ។ ព័ត៌មាននេះនឹងផ្តល់ឱ្យស្ថាប័នរាជរដ្ឋាភិបាលនូវការយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពនៅទីវាល ដែលអាចធ្វើការសម្រេចចិត្តតែកាន់ប្រសើរឡើងតាមរយៈការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយលើការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការស្តារស្ថានភាពក្រោយមានភ្លើងឆេះ និងដឹកនាំការកែប្រែគោលនយោបាយភ្លើងឆេះរបស់ប្រទេសនៅពេលដែលចាំបាច់។ តំបន់ដែលបានឆេះអាចឱ្យដឹងបានតាមរយៈការប្រៀបធៀបរូបភាពពីផ្កាយរណបឬជ្រូនមុន និងក្រោយឧប្បត្តិហេតុភ្លើងឆេះ ដើម្បីកំណត់ពីការបាត់បង់នូវរុក្ខជាតិ និងទំហំទីវាលដែលត្រូវបានភ្លើងឆេះរុក្ខជាតិអស់។ ការស្វែងរកនូវមូលហេតុដែលបង្កឱ្យមានភ្លើងឆេះគឺជាការចាំបាច់ដើម្បីកំណត់រកប្រភព និងជនល្មើសដែលបង្កអគ្គីភ័យ។

## ការធ្វើផែនការ និងការសម្របសម្រួល

ដោយផ្អែកទៅលើទិន្នន័យដែលប្រមូលបាន ក្រុមការងារអន្តរកម្មសិក្សាគួរតែមានការចូលរួមពីស្ថាប័នរាជរដ្ឋាភិបាលដើម្បីវាយតម្លៃពីការខូចខាត និងការខាតបង់ ក៏ដូចជាធ្វើការណែនាំពីការស្តារស្ថានភាពតំបន់ដែលរងផលប៉ះពាល់ឡើងវិញឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យតំបន់នោះអាចវិលមករកសភាពដើមឡើងវិញ។ បន្ទាប់មកតំបន់ទាំងនោះគួរតែត្រូវបានផ្តល់អាទិភាពតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលកំណត់ដោយគោលនយោបាយផ្ទៃក្នុង។

## ធនធាន

ធនធានអាចត្រូវបានបែងចែកសម្រាប់ការស្តារតំបន់ដែលរងផលប៉ះពាល់ ធ្វើការស្រាវជ្រាវដើម្បីកំណត់ពីវិធីសាស្ត្រដាំដុះល្អបំផុតដែលអាចធ្វើឡើងវិញបាន។ ប្រសិនបើអាចអនុវត្តបាន ក្រុមការងារមនុស្សធម៌ និងសង្គមក៏គួរតែត្រូវបានយកមកពិចារណាផងដែរ ដើម្បីបង្កើតមជ្ឈមណ្ឌលផ្តល់ជំនួយ និងគាំទ្រដល់សហគមន៍ដែលរងផលប៉ះពាល់។

## ការផ្សព្វផ្សាយជាសាធារណៈ

ការចូលរួម និងការអប់រំជាសាធារណៈពីសារៈសំខាន់នៃការបន្តការពារ និងស្តារឡើងវិញនូវតំបន់ដីមមោកដែលរងការខូចខាតគឺជាការចាំបាច់ ដើម្បីធានាបាននូវភាពជាម្ចាស់ និងសិទ្ធិ ក្នុងការការពារតំបន់ដីមមោកដែលនៅសេសសល់។ កិច្ចខិតខំប្រឹងប្រែងនេះអាចទទួលបានការគាំទ្រតាមរយៈការ ផ្តល់ជាព័ត៌មានពីកម្មវិធីផ្តល់ជំនួយផ្នែកបរិស្ថាន និងសង្គមផ្សេងៗ។




© Nanang Sujana/CIFOR

Global Environment Centre

CIFOR

IFAD
Investing in rural people

asean

ការបោះពុម្ពផ្សាយ
កំណែពេញលេញ